# ដំណាំត្រសក់ចំណារ

## I. ស្ថានភាពទូទៅ

ដំណាំត្រសក់ត្រូវបានគេជឿជាក់ថា មានប្រភពនៅប្រទេសឥណ្ឌា ក្រោយមកក៏រីករាលដាលទៅប្រទេសអេស៊ីប ប្រទេសក្រិច ចិន ឥណ្ឌូនេស៊ី ប្រទេសថៃ និងនៅទ្វីបអាមេរិក ។





ដំណាំប្រភេទនេះ គេចាត់បញ្ចូលទៅក្នុងដំណាំត្រូវការអាកាសធាតុក្តៅមធ្យមចន្លោះ ១៨-៣០ºC

- ត្រសក់ចំណារស្ថិតក្នុងលំដាប់គ្រួសារគូកូប៊ីតាសេ ។ គេចែកចេញជាពីរប្រភេទ គឺប្រភេទសំបករលោង និង សំបកគ្រើម។ វាជាប្រភពនៃវីតាមីន និងសារធាតុរ៉ែផ្សេងៗក្នុងទម្ងន់១០០ក្រាមដែលអាចបរិភោគបានផ្លែខ្ចី ដូចជាៈ

| សារធាតុសំខាន់ៗ | ក្នុងទម្ងន់១០០ក្រាមដែលអាចបរិភោគបាន |
|---|---|
| ទឹក | ៩៦,៣ក្រាម |
| ប្រូតេអ៊ីន | ០,៤៤ក្រាម |
| ប្រេងខ្លាញ់ | ០,៥ក្រាម |
| ថាមពល | ១៣គីឡូកាឡូរី |
| កាល់ស្យូម | ១០មីលីក្រាម |
| ផូស្វាត | ២៥មីលីក្រាម |
| ដែក | ១,៥មីលីក្រាម |
| វីតាមីនសេ | ៧មីលីក្រាម |

## II. បច្ចេកទេសដាំដុះ

ដើម្បីទទួលបានទិន្នផលពីការដាំដុះដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ ត្រូវមានការងារច្រើនដែលត្រូវអនុវត្ត ដូចតទៅ៖

### *១.ការជ្រើសរើសពូជ*

ការជ្រើសរើសពូជជាកត្តាសំខាន់បំផុតនៅក្នុងការដាំដុះព្រោះពូជមានលក្ខខណ្ឌផ្សេងៗពីគ្នា ហើយត្រូវបានចែកចេញជា ៣ប្រភេទដូចតទៅ ៖







- *ពូជស្រាល:* ពូជនេះមានអាយុកាលលូតលាស់ខ្លីគឺប្រមាណពី **<u>៣៥-៤០ថ្ងៃ</u>**ក្រោយដាំ ភាគច្រើនគឺផ្លែល្អិតតូចៗជាចង្កោមៗមានបន្លាច្រើនជួរតាមបណ្តោយនៃផ្លែទទឹងផ្លែមិនលើស ១,៥ស.ម ប្រវែងជាមធ្យម ៨-១០ ស.ម។ សន្លឹកល្អិតដើមតូចផ្កាឈ្មោលច្រើនតាមថ្នាំងនៃដើម ហើយមានរោមក្រាស់លើផ្ទៃស្លឹក និងដើមគ្រាប់តូចល្អិតស្រួចៗ ហើយខ្លីទម្ងន់ ១០០គ្រាប់មានចំនួន ២,៥-៤ ក្រាម ប្រភេទនេះគេឲ្យឈ្មោះថា **ត្រសក់បន្លា ឬត្រសក់ជ្រក់**។





- *ពូជកណ្តាល:* ពូជនេះមានអាយុកាលលូតលាស់មធ្យម គឺប្រមាណពី **<u>៤០-៥០ថ្ងៃក្រោយដាំ</u>**។ ផ្លែភាគច្រើនមានព័ណ៌បៃតងស្រាល ផ្នែកខាងគូទមានព័ណ៌លឿងខ្ចី ផ្លែច្រើនរាយៗមិនចង្កោម ទទឹងផ្លែមាន ប្រវែង ៣-៤ស.ម បណ្តោយផ្លែប្រវែងពី ១០-១៣ស.ម រាងរបស់ផ្លែវាធំកណ្តាលតូចក្បាល និងកន្ទុយ ពូជនេះកសិករភាគច្រើនដាំនៅតាមសួនបន្លែ មិនមានលក្ខណៈទ្រង់ទ្រាយជាផលិតកម្មធំៗឡើយ ព្រោះទិន្នផលរាប់ពី **<u>៦-៨តោនក្នុង១ហិកតា</u>**។ លក្ខណៈសំគាល់គឺ ស្លឹកធំ ស្តើងរាងមូល រោមខ្លីៗមានព័ណ៌បៃតងធម្មតាគ្រាប់សំប៉ែតធំខ្លី ។

- *ពូជធ្ងន់:* ពូជនេះមានអាយុកាលលូតលាស់វែងប្រមាណពី **៥០-៧០ថ្ងៃក្រោយដាំ**។ ផ្លែរបស់វាទ្រវែងមានព័ណ៌បៃតងចាស់ប្រមាណ ២/៣ នៃប្រវែងផ្លែ ។ មានថ្នាំងរង្វើលបែកមែកមធ្យម ស្លឹកធំក្រាស់ហើយស្រួច

មានរោមរឹងទទឹងផ្លែជាមធ្យម ៣,៥ស.ម ប្រវែងជាមធ្យម ១២-២០ស.ម រូបសណ្ឋាននៃគ្រាប់ ទ្រវែងស្រួចកំប៉ោងកណ្តាលទម្ងន់ ១០០គ្រាប់ពី**៣,៥-៥,៥ក្រាម** ច្រើនដាំនៅខេត្តកណ្តាល កំពង់ឆ្នាំង និងកំពង់ចាម ។ ត្រសក់មិនមែនជាដំណាំប្រកាន់រដូវឡើយ ប៉ុន្តែពូជត្រសក់ក្រោយពីសំរាំងគ្រាប់ ហើយត្រូវការសំរាករយៈពេលពី **៤-៦ខែ ទើបអាចដាំដុះបាន** ។ លក្ខណៈពិសេសមួយទៀតគឺបច្ចុប្បន្នមានពូជ ២ប្រភេទ គឺពូជគ្មានជំនាន់អាចដាំបានហើយទុកពូជបាន ប៉ុន្តែពូជបង្កាត់មិនអាចទុកពូជបានឡើយ ។ សេចក្តីត្រូវការពូជសម្រាប់ដាំលើផ្ទៃដី១ហ.ត គឺ **៣,៥ ទៅ ៥គក្រ** អាស្រ័យទៅតាមភាគរយដំណុះ និង ចន្លោះគុម្ពនៃការដាំ ។

## *២.ការជ្រើសរើសរដូវ*

- សម្រាប់លក្ខខណ្ឌប្រទេសកម្ពុជា ដំណាំត្រសក់មិនមែនជាដំណាំដែលប្រកាន់រដូវឡើយ វាអាចដុះលូតលាស់បានចន្លោះសីតុណ្ហភាពពី ២០-៣០ºC ។ ប៉ុន្តែរដូវសមស្របបំផុតគឺនៅចុងរដូវវស្សាចាប់ពី ខែតុលា ដល់ខែកុម្ភៈ ព្រោះក្នុងអំឡុងពេលនោះត្រសក់អាចលូតលាស់ល្អ ទិន្នផលខ្ពស់បណ្តាលមកពីកត្តា សីតុណ្ហភាពចុះទាប សំណើមបរិយាកាសខ្ពស់ ភ្លៀងមិនអូសបន្លាយសីតុណ្ហភាពដីប្រែប្រួលទាបរយៈពេល ពន្លឺថ្ងៃមានកំរិតសមស្រប ។ ប៉ុន្តែត្រសក់ជួបកត្តាលំបាកជាច្រើនចាប់ពីខែមីនា ដល់ខែឧសភា គឺសត្វល្អិត ជម្ងឺបំផ្លាញច្រើនបណ្តាលមកពីលក្ខខណ្ឌអាកាសធាតុមិនសមស្របធ្វើឲ្យត្រសក់មានទិន្នផលទាប ។ តែនៅរដូវវស្សាវិញចាប់ពីខែមិថុនា ដល់ខែកញ្ញា ត្រសក់ច្រើនជួបជម្ងឺបំផ្លាញច្រើនជាងសត្វល្អិតបណ្តាលមកពីសំណើមដី និងសីតុណ្ហភាពដីប្រែប្រួល ។

## *៣.ការជ្រើសរើស និងរៀបចំដី*

- ***ការជ្រើសរើសដី*** *:* ត្រសក់ត្រូវការដីមានជីជាតិគ្រប់គ្រាន់ សំបូរទៅដោយសារធាតុចិញ្ចឹម និងបន្ទុកខ្យល់គ្រប់គ្រាន់សម្រាប់ត្រសក់ គឺដីប្រភេទដីល្បប់មាត់ស្ទឹង បឹង ទន្លេ និងដីល្បាយខ្សាច់មិនដក់ទឹកក្រោយពេលភ្លៀងធ្លាក់កាលណាទឹកដក់លើសពី ៤ម៉ោងឡើងទៅ ធ្វើឲ្យត្រសក់ងាយកើតជម្ងឺទុំស្លឹក។ ក្រៅពីនោះវាអាចលូតលាស់ល្អដែរនៅលើប្រភេទដីក្រហម និងដីខ្មៅក្នុងតំបន់ខ្ពង់រាប ប៉ុន្តែដីឥដ្ឋ ឬដីជូរត្រសក់លូតលាស់មិនល្អឡើយ។ កាលណាដីដែលធ្លាប់ដាំដំណាំប្រភេទអំបូរត្រសក់ជាច្រើនលើករួចមកគេត្រូវបន្ថែមជីលាមកសត្វជាច្រើនតោនក្នុង ១ហិកតា ចន្លោះពី ២០-៣០តោន។ ដីដែលសមស្របខ្លាំងមានប៉េហាស់ ៦,៥-៧,៥ កាលណាប៉េហាស់**ទាបជាង៤** ត្រូវផ្អាកការដាំត្រសក់រយៈពេល ១-២ឆ្នាំ ត្រូវដាំដំណាំអំបូរសណ្តែកដើម្បីកែលំអដី ។
- ***ការរៀបចំដី*** *:* ត្រូវរាស់ប្រមូលយកស្មៅនិងដំណាំផ្សេងៗពីរដូវមុនចេញ ភ្ជួរហាលដីលើកទី១ ឲ្យជ្រៅ ត្រឡប់ស្រទាប់ដីពីក្រោមឡើងលើ និងហាលដីឲ្យបានច្រើនសប្តាហ៍ក្នុងគោលបំណងបន្ថយនូវភ្នាក់ងារចម្លងជម្ងឺនិងសត្វ ល្អិត ព្រមទាំងឲ្យស្មៅចង្រៃងាប់ ជាពិសេសគឺប្តូរទម្រង់ដីនិងពង្រាយជីជាតិ ។ ការភ្ជួរ ត្រូវធ្វើឲ្យបាន ២-៣លើក មុននឹងលើករងដាំដុះ ។ ការលើករងសម្រាប់ដាំគឺអាស្រ័យទៅតាមវិធីដាំនិងជីជាតិរបស់ដី។ កាលណាដាំដោយ ដោតចំណារបញ្ឈរទទឹងរងត្រូវមានប្រវែង ១២០ស.ម កំពស់រង ២៥-៣០ស.ម ។ ប៉ុន្តែបើដាំឲ្យវារនៅលើដីទទឹងរងមានប្រវែង ៨០ ទៅ ១០០ស.ម តែការដាំតាមវិធីនេះត្រសក់មានផ្លែចំនួនតិច ទិន្នផលទាប។ នៅក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ ដីរក្សាសំណើមគ្របដីមុនពេលដាំដើម្បីបន្ថយកំដៅដី ស្មៅរក្សាសំណើមបានយូរនិងឲ្យ ដីធូរមិនហាប់កាលណាដីហាប់បណ្តាលឲ្យបន្ទុកខ្យល់មិនគ្រប់គ្រាន់ និងប្រវែងឫសចាក់បានតិច ។

*៤.វិធីសាស្ត្រដាំដុះ*

មុននឹងដាំ ត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃឲ្យក្តៅរយៈពេល១-២ម៉ោង បន្ទាប់មកយកទៅត្រាំទឹករយៈពេល ៤ ទៅ៥ម៉ោង បន្ទាប់ត្រូវលាងសំអាតគ្រាប់ឲ្យស្អាត ចំនួន ៣-៤លើក មុនពេលផ្អាប់ត្រាំគ្រាប់ពូជ។ ការផ្អាប់ត្រូវយកក្រណាត់ជ្រលក់ទឹកឲ្យជោកយកមកខ្ចប់គ្រាប់នោះហើយកប់ទៅក្នុងដីសើមៗរយៈពេល ១យប់។ មុនដាំត្រូវយកគ្រាប់ពូជមកលាយជាមួយនឹងថ្នាំសម្លាប់ផ្សិតប្រភេទកាប់តង់,ស៊ីណែប,ម៉ង់កូសែប **ក្នុងកំរិត២% ឬ ១គក្រគ្រាប់ពូជបរិមាណថ្នាំកន្លះស្លាប ព្រាបាយ** ច្របល់ឲ្យសព្វយកទៅដាំដោយប្រើចន្លោះគុម្ព២៥ស.ម ចន្លោះ ជួរ៦០ស.ម ជម្រៅ២-៣ស.ម គ្រាប់ក្នុងមួយគុម្ព ហើយគ្របពីលើដោយកំណាត់ចំបើងខ្លីៗ ឬជីធម្មជាតិពុករលួយល្អ វិធីនេះគឺដាំឲ្យត្រសក់ឡើងតោងចំណារបញ្ឈរ ប៉ុន្តែការដាំឲ្យវារលើដីត្រូវប្រើចន្លោះជួរ៨០ស.ម ចន្លោះគុម្ព ៥០ស.ម, ៣-៤គ្រាប់ ក្នុងមួយគុម្ព តែគ្របគុម្ពដូចគ្នា ។ ក្រោយពីដាំភ្លាមត្រូវពិនិត្យមើលសំណើមដី កាលណាដីស្ងួតខ្លាំងត្រូវតែស្រោចទឹកក្រោយដាំ ហើយដើម្បីឲ្យត្រសក់ដុះស្មើគ្នាងាយថែទាំ ។ ក្រោយពីដាំរយៈពេល៣ទៅ ៤ថ្ងៃ ក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ ៣០អង្សាសេ និងពេលយប់ ១៨-២០អង្សាសេ ធ្វើឲ្យត្រសក់លូតលាស់លឿន។





*៥.របៀបស្រោចស្រព*

ដំណាំត្រសក់ជាប្រភេទដំណាំត្រូវការទឹកជាប្រចាំ ប៉ុន្តែសំណើមដីមិនលើសពី៥០-៧០%ឡើង។ សេចក្តីត្រូវការទឹកចែកចេញជាបីវគ្គ ៖

- **វគ្គលូតលាស់** : ចាប់ពីត្រសក់ដុះរហូតដល់ត្រសក់បោះដៃ និងមានផ្កាក្រពុំវាត្រូវការសំណើមដីជាមធ្យមប្រមាណ ពី៥០-៦០% ។ របៀបស្រោចដោយបាញ់ទឹកពីលើល្អជាងការស្រោចដោយបញ្ចូលតាមចន្លោះជួរ គឺ១ថ្ងៃម្តង ឬ ២ដងទៅ តាមប្រភេទដី និងអាកាសធាតុ បរិមាណទឹកក្នុងវគ្គនេះមានប្រមាណ ពី **១៤០០ - ១៦០០ម$^{៣}$/ហ.ត** ។

- **វគ្គបន្តពូជនិងផ្លែ** : ចាប់ពីត្រសក់មានអាយុពី១៥ថ្ងៃឡើងទៅវានឹងមានផ្កាឈ្មោលចេញតាមថ្នាំង ប៉ុន្តែមិនទាន់រីក។ វគ្គនេះត្រូវការសំណើមដីពី ៦០-៧០% គឺជាវគ្គដែលត្រូវការទឹកច្រើនជាងគេរហូតដល់ត្រសក់មានអាយុ ៣០-៤០ថ្ងៃក្រោយដាំ ប៉ុន្តែការស្រោចដោយបញ្ចូលតាមចន្លោះរងមួយអាទិត្យ២-៣ លើកជាការល្អ ព្រោះការស្រោចដោយបាញ់ទឹកពីលើធ្វើឲ្យប៉ះពាល់ដល់ការបន្តពូជបរិមាណទឹកសរុប ក្នុងវគ្គនេះមានពី **១៨០០ ទៅ ២០០០ម$^{៣}$/ហ.ត** ។

- **វគ្គចេញផ្លែ** : ១០០% ចាប់ពីការប្រមូលផល ១-២លើក ត្រសក់ត្រូវការសំណើមដីទាបមកវិញ គឺពី ៥០-៦៥% កាលណាការបញ្ចូលទឹកលើសពីនេះធ្វើឲ្យត្រសក់ចាប់ប្រែព័ណ៌ពីបៃតងទៅលឿង ។

*៦.ដកស្មៅនិងជ្រំជ្រាយដី*

ការជ្រំជ្រាយដីត្រូវធ្វើឡើងនៅពេលត្រសក់មានសន្លឹកពិតចំនួន ២ គឺនៅពេលទងរបស់វាលូតវែង (១០-១៥ថ្ងៃក្រោយដាំ) ត្រូវជ្រំបំបែកដីសើរៗហើយកៀរយកដីពីបាតរងមកលប់គល់ឲ្យជិតក្នុងករណីដីដែលដុះស្មៅ ត្រូវដកយកស្មៅចេញមុនជ្រំជ្រាយដី។ ចំពោះការដាំដោយគ្របនឹងកៅស៊ូខ្មៅមិនចាំបាច់ជ្រំជ្រាយដីឡើយ។ ការជ្រំជ្រាយដី គឺប្រយោជន៍ធ្វើឲ្យដីធូរជ្រាបទឹកបានល្អ រក្សាសំណើមបានយូរ ធ្វើឲ្យខ្យល់ចេញចូលបានល្អបន្ថយការលូតលាស់របស់ស្មៅ។

*៧.ការដោតចំណារ*

ការដោតចំណារមានសារៈសំខាន់ដោយបង្កើនទិន្នផលនិងបន្ថយការរាតត្បាតអំពីជម្ងឺនិងសត្វល្អិត។ ការដោតចំណារ ត្រូវយកមែកឈើក្រៀមៗគ្មានស្លឹកមកដោតបញ្ឈរក្បែរៗគុម្ពឲ្យញឹកហើយចងឲ្យជាប់ការការពារដួលរលំ គេធ្វើឡើងក្រោយពីដាំរយៈពេល ១០-១៥ថ្ងៃ គឺក្រោយពីជ្រំជ្រាយដី។

*៨.ការប្រើប្រាស់ជី*

ដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ វាត្រូវការសារធាតុចិញ្ចឹម៣យ៉ាងសំខាន់គឺ អាសូត ផូស្វ័រ ប៉ូតាស្យូម និងសារធាតុផ្សេងៗទៀត ។ ប៉ុន្តែសារធាតុទាំងនោះវាត្រូវការទៅតាមដំណាក់កាលរបស់វាដូចជាដំណាក់កាលលូតលាស់ដើម ស្លឹក វាត្រូវការអាសូតច្រើនជាងគេ បន្ទាប់មកគឺធាតុប៉ូតាស្យូម ប៉ុន្តែផូស្វ័រវាត្រូវការបន្តិចម្តងៗ ចាប់ពីវគ្គកំណកំណើតផ្កាដោយបរិមាណក្នុងមួយវដ្តជីវិតតិចជាងគេ។ ដូចនេះការប្រើប្រាស់ជីត្រូវដាក់ទៅតាមដំណាក់កាលរបស់វា ៖

- មុនពេលដាំគេតែងដាក់ជីធម្មជាតិឲ្យបានច្រើនពី ១៥ទៅ២០តោន ក្នុង ១ហិកតា និងជីគីមីប្រភេទ ១៥.១៥.១៥ ចំនួន១៥០គក្រ។ ជីទាំងនោះត្រូវដាក់ទៅក្នុងបាតរណ្តៅហើយជ្រំដីលប់ឲ្យជិតពីលើទើបធ្វើការដាំដុះតាមក្រោយ។
- ក្រោយពេលដាំរយៈពេល១០ទៅ១៥ថ្ងៃគេត្រូវយកជីអាសូតសុទ្ធ(អ៊ុយរ៉េ) ចំនួន ២៥ទៅ៣០គក្រ មក លាយទឹកស្រោចចំៗគុម្ព បន្ទាប់មកស្រោចទឹកលាងតាមក្រោយ ។
- នៅក្នុងវគ្គត្រសក់ចេញផ្កា១០០% គេយកជីគីមីប្រភេទ១៥.១៥.១៥ ដដែល ចំនួន១០០គក្រ មកដាក់តាមចន្លោះគុម្ព ហើយលប់ដីឲ្យជិតបន្ទាប់មកស្រោចទឹកឲ្យជោគ។

## III. **អំពីជម្ងឺនិងសត្វល្អិត**

*១.អំពីជម្ងឺផ្សិត*

- ត្រសក់រងការបំផ្លាញដោយជម្ងឺផ្សិតច្រើនប្រភេទ ហើយគ្រប់វគ្គលូតលាស់វគ្គបន្តពូជ និងវគ្គទុំនៃផ្លែ ។

★ **ជម្ងឺរលាកនៃគល់កូនដំណាំ**: វាបង្កដោយក្រុមផ្សិតច្រើនប្រភេទរោគសញ្ញាគឺចាប់ផ្តើមរលាកគល់ដំណាំក្នុងដំណាក់កាល ៥-៧ថ្ងៃ ក្រោយដុះធ្វើឲ្យរលាកជាំៗគល់ ក្រោយមកក៏ចាប់ផ្តើមដួលរលំ ហើយរីករាលដាលកាន់តែច្រើនឡើងៗលើរងកូនដំណាំ ។ លក្ខខណ្ឌគឺកូនដំណាំស្លោកជាប់មកជាមួយគ្រាប់ដី ថ្នាលសំណាបមានមេរោគ សំណើមដីខ្ពស់លើសពី ៧០% គ្មានខ្យល់អាកាស និងពន្លឺគ្រប់គ្រាន់។

★ **ជម្ងឺស្ងួតស្លឹកពណ៌ត្នោត:**

- **រោគសញ្ញា** : ដំបូងស្លឹកត្រសក់ឡើងលឿងផ្ទាំងៗក្រោយមកទៅជាស្ងួតហើយប្រែពណ៌ទៅត្នោតប្រផេះពីស្លឹកក្រោមឡើងមកលើធ្វើឲ្យស្លឹកដំណាំស្ងួតពីដើមមួយទៅដើមមួយ ហើយរីករាលដាលយ៉ាងរហ័ស។
- **លក្ខខណ្ឌបំផ្លាញ** : នៅរដូវវស្សាភាគច្រើនជាងរដូវប្រាំង បណ្ដាលមកពីសំណើមដីខ្ពស់អាកាសធាតុក្ដៅ ចន្លោះគុម្ពញឹក ចំនួនដើមក្នុងគុម្ពលើសកំណត់ពន្លឺមិនគ្រប់គ្រាន់ខ្យល់អាកាសមិនល្អ។

★ **ជម្ងឺរលួយឫស និងស្ងួតបណ្ដូលនៃដើម**

- **រោគសញ្ញា** : ក្នុងដំណាក់កាលកូនដំណាំខ្ចីៗធ្វើឲ្យស្វិតរញមស្រពោនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែស្រពោនឡើងៗ ដើមរបស់ដំណាំស្ងួតបណ្ដូល ឫសរបស់វាប្រេះហើយជាំៗ។
- **លក្ខខណ្ឌបំផ្លាញ** : ជម្ងឺរស់នៅក្នុងដី និងទឹក ហើយវាឆ្លងពីចំការមួយទៅចំការមួយ ពីដើមមួយទៅដើមមួយ ដោយទឹក និងកាកសំណល់ដំណាំ អាកាសធាតុក្ដៅ និងសំណើមដីខ្លាំងលើសពី ៧៥% ងាយនឹងកើត។

★ **ជម្ងឺក្រាម្សៅលើស្លឹក :**

- **រោគសញ្ញា** : ដំបូងសង្កេតឃើញលេចចេញចំណុចពណ៌លឿងតូចៗលើស្លឹក ក្រោយមកមានស្នាមម្សៅកញ្ចុំៗរាងរង្វង់រយៈពេលតែ ២ទៅ៣ថ្ងៃ រង្វង់ម្សៅនេះរីករាលដាលពេញស្លឹកទាំងស្លឹកខ្ចីក៏ដូចស្លឹកចាស់។
- **លក្ខខណ្ឌកំណើត**: ច្រើនកើតនៅរដូវប្រាំងពេលអាកាសធាតុត្រជាក់ស្ងួត មេរោគចូលចិត្តរស់នៅតាមដើមឈើព្រៃ និងឈើហូបផ្លែ រដូវភ្លៀងមិនធ្វើឲ្យមានលក្ខណៈធ្ងន់ធ្ងរឡើយ។

**២-ជម្ងឺបង្កឡើងដោយវីរុស**

- ជម្ងឺដែលបង្កដោយវីរុសមានច្រើនប្រភេទលើដំណាំត្រសក់ដូចជា :

★ **ជម្ងឺរួញស្លឹកខ្សូរចុះក្រោម :**

- រោគសញ្ញាដំបូង

  វាលេចចេញចំណុចខ្លះនៅលើស្លឹកគឺសភាពរួញជាពិសេសស្លឹកខ្ចីៗក្នុងដំណាក់កាលលូតលាស់ធ្វើឲ្យមិនអាចរីកធំធាត់បាន ព្រមទាំងធ្វើឲ្យផ្លែពកៗក្រឡាៗហើយរឹងសំបក សាច់ត្រសក់គ្មានរសជាតិវារីកនឹងរាលដាលចម្លងដោយក្រុមចៃ។

**វិធានការការពារនិងកំចាត់**: គឺជ្រើសរើសពូជគ្មានជម្ងឺ កំចាត់ស្មៅឲ្យស្អាត និងការពារចៃកុំឲ្យបំផ្លាញត្រសក់។

**៣-សត្វល្អិត:**

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលបំផ្លាញដំណាំ ក្នុងនោះមានសត្វល្អិតជាភ្នាក់ងារបង្ករោគ និងសត្វល្អិតបំផ្លាញផ្ទាល់។ សត្វល្អិតជាភ្នាក់ងារចម្លងមាន :

- **ចៃបៃតង:** រោមជញ្ជក់ស្លឹកធ្វើឲ្យត្រសក់រួញស្លឹកហើយខ្សូរចុះក្រោម
- **មមាចជញ្ជក់ស្លឹក:** វាមានពីរប្រភេទ មាឌតូច និងមាឌធំតែងជញ្ជក់ស្លឹកធ្វើឲ្យស្លឹកត្រសក់ស្ងួតគែម ហើយស្លឹកឡើងលើ។
- **រុយស:** រុយប្រភេទនេះមានមាឌតូចៗពណ៌ស ហើយមើលនឹងភ្នែកទទេស្ទើរមិនឃើញ គេអាចសង្កេតវាបានដោយត្រូវពិនិត្យមើលក្រោមស្លឹកពេលថ្ងៃក្ដៅ។

ដើម្បីការពារទៅនឹងកត្តាចង្រៃទាំងនេះ គេត្រូវអនុវត្តវិធីសាស្ត្រច្រើនយ៉ាងដូចជាជ្រើសរើសរដូវ ផ្លាស់ប្តូរ មុខដំណាំ ជ្រើសរើសពូជធន់ទ្រាំ រៀបចំដីឲ្យបានត្រឹមត្រូវសំអាតស្មៅក្នុងចំការ ជាពិសេសគ្រប់គ្រងវត្ថមានសត្វល្អិតមុនពេលវាពេញវ័យ បន្ទាប់មកអនុវត្តវិធានការដើម្បីកំចាត់។




## IV. ការប្រមូលផល

### ១-ការប្រមូលផល

- ការប្រមូលផលគឺធ្វើឡើងក្រោយពីការដាំរយៈពេលខុសគ្នា ទៅតាមប្រភេទពូជ និងអាស្រ័យទៅតាមសេចក្តីត្រូវការដូចជាៈ
- <u>ពូជស្រាល</u> : គឺគេអាចប្រមូលផលដំបូងក្រោយពីការដាំរយៈពេល៣៥ទៅ៤០ថ្ងៃគឺបេះផ្លែដោយយកកន្ត្រៃកាត់ត្រឹមទងនៃផ្លែ ហាមប្រឡេះយកតែផ្លែបណ្តាលឲ្យផ្លែត្រសក់ឆាប់ក្រហមប្រែពណ៌ ប្រភេទពូជនេះទិន្នផលមធ្យមចន្លោះពី ៨ - ១០តោន ក្នុងមួយហិកតា។
- <u>ពូជកណ្តាល</u> : គឺការប្រមូលផលដំបូងក្រោយដាំរយៈពេល៤៥ទៅ៥០ថ្ងៃ ការបេះគឺកាត់យកផ្លែដូចជា ត្រសក់ឯទៀតដែរ។ ការបេះយកផ្លែស្រស់មានចំនួនពី <u>**៥ទៅ៧លើក**</u> ហើយទិន្នផលជាមធ្យម១០ ទៅ ២០ តោន ក្នុង១ហ.ត។
- <u>ពូជធ្ងន់</u>:ធ្វើការប្រមូលផលបានច្រើនលើកពី<u>**៥ ទៅ ១០លើក**</u> ហើយទិន្នផលមធ្យមពី <u>**១០ទៅ១៥តោន**</u> ក្នុងមួយហិកតា ។




### ២-ការប្រមូលផលពូជ:

ដើម្បីឲ្យពូជនៅជំនាន់ក្រោយទទួលបានភាពសុទ្ធល្អការជ្រើសរើសត្រូវអនុវត្តទៅតាមវិធីសាស្ត្រខាងក្រោម ៖

- ដើមគ្មានជម្ងឺ និងសត្វល្អិតបំផ្លាញ

- ដើមលូតលាស់ធម្មតា មានលក្ខណៈតែមួយផ្នែកសំខាន់ៈគឺថ្ងៃ ខែ ចេញផ្កា ស្លឹកពណ៌ និងទ្រង់ទ្រាយផ្លែ មានលក្ខណៈដូចគ្នាទាំងពណ៌និងទំហំ។ ផ្លែដែលមុនគេ(ផ្លែដំបូង)ត្រូវកាត់ចោលទុកតែផ្លែលើកទី ២ទី៣ ក្រៅពីនេះកាត់ ចោល ហើយផ្លែទាំងនោះត្រូវបេះមកទុកដោយឡែកៗពីគ្នា គឺទី ២ទុកដោយទី២ ទី៣ទុកដោយទី៣ នៅពេល ផ្លែទុំក្រហមប្រេះបែកក្រឡា ក្រោយពីបេះហើយត្រូវរក្សាទុកពី ៤ទៅ៥ថ្ងៃ ទើបពុះផ្លែយកគ្រាប់ត្រាំទឹកមួយយប់ បន្ទាប់មកលាងទឹកសំអាតយកគ្រាប់ដែលល្អមកដាក់ហាលថ្ងៃរយៈពេល ១ទៅ២ថ្ងៃ (ហាមហាលថ្ងៃត្រង់និងលើ ឧបករណ៍ដែក) ក្រោយមកទុកគ្រាប់ឲ្យត្រជាក់ទើបប្រមូលយកគ្រាប់ដាក់ដប ឬកញ្ចប់ហើយបិទជិតរក្សាទុកនៅកន្លែងស្ងួតធម្មតាហាមត្រូវកំដៅថ្ងៃ ។